

លំនៅឋានមនុស្សជាតិកម្ពុជា
Habitat for Humanity®
Cambodia

# ការអភិវឌ្ឍន៍សហគមន៍ លើសពីការសាងសង់លំនៅឋាន

## ការផ្តល់ភាពអង់អាចឱ្យសហគមន៍មានភាពធន់ និងផលជះ

## ប្រចាំឆ្នាំសារពើពន្ធ២០២៤ (FY24)

១កក្កដា ២០២៣ - ៣០មិថុនា ២០២៤

# តារាងមាតិកា


១ វិស័យដែលយើងអភិវឌ្ឍ ........ ៤

២ សារស្វាគមន៍ពីនាយកប្រចាំប្រទេសស្តីទីរបស់យើង ........ ៦

៣ បេសកកម្ម ចក្ខុវិស័យ និងគោលការណ៍ស្នូលរបស់យើង ........ ៨

៤ អំពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ........ ៩

៥ ទិដ្ឋភាពទូទៅនៅប្រទេសកម្ពុជា ........ ១០

៦ ការណែនាំអំពីក្របខណ្ឌយុទ្ធសាស្ត្រថ្មីរបស់យើង ........ ១២

៧ ផលជះក្នុងឆ្នាំ FY24៖ គ្រួសារដែលទទួលជំនួយពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ........ ១៣

៨ គម្រោង HOME-LIFT: ........ ១៤

៨.១ លើកកម្ពស់ជីវភាពតាមរយៈការសាងសង់លំនៅឋាន ........ ១៤

៨.២ លើកកម្ពស់ជីវភាពតាមរយៈវិធីសាស្ត្រប៉ាសា ........ ១៦

៨.៣ លើកកម្ពស់ជីវភាពតាមរយៈការផ្លាស់ប្តូរសិទ្ធិកាន់កាប់ ........ ២០

៩ ភាពធន់របស់សហគមន៍: ........ ២៤

៩.១ ការបង្កើតសហគមន៍ដែលមាននិរន្តរភាព ........ ២៤

៩.២ ការសាងសង់លំនៅឋានដែលធន់នឹងអាកាសធាតុ ........ ២៦

៩.៣ ដំណោះស្រាយទឹកស្អាត និងអនាម័យដែលមាននិរន្តរភាព ........ ២៨

១០ កសាង និងបង្កើតផលជះ៖ ........ ៣២

១០.១ កសាងឱ្យបានច្រើនជាងមុន (MAATCH) ........ ៣២

១០.២ សិក្ខាសាលាស្តីពីបញ្ហាប្រឈមនៃលំនៅឋានតម្លៃសមរម្យក្នុងប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍន៍ទីក្រុង ........ ៣៥

១០.៣ បណ្តាញរបស់អង្គការមិនមែនរដ្ឋាភិបាលផ្នែកលំនៅឋានក្នុងប្រទេសកម្ពុជា ........ ៣៦

១១ ការពង្រីកផលជះសង្គមតាមរយៈការស្ម័គ្រចិត្ត ........ ៣៨

១២ ទិដ្ឋភាពទូទៅនៃហិរញ្ញវត្ថុ ........ ៤២

១៣ ការថ្លែងអំណរគុណសម្រាប់ការកសាងជាមួយយើង! ........ ៤៤



# ១ តំបន់នៃប្រតិបត្តិការណ៍របស់យើង




ការិយាល័យរបស់យើង

ប្រតិបត្តិការគម្រោង FY24

គម្រោងពីមុន

តំបន់ដែលពង្រីក



# ២ សារស្វាគមន៍ពីនាយកស្ដីទីប្រចាំប្រទេសរបស់យើង



## ជំរាបសួរ!

សូមគោរពដល់អ្នកឧបត្ថម្ភ ដៃគូ និងមិត្តភក្តិរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា ខណៈពេលដែលខ្ញុំឆ្លុះបញ្ចាំងលើវឌ្ឍនភាពសំខាន់ៗ និងបញ្ហាប្រឈមពីឆ្នាំមុនមក ខ្ញុំមានតែសេចក្តីថ្លែងអំណរគុណដល់ការប្តេជ្ញាចិត្ត និងការតាំងចិត្តដ៏មោះមុតសមាជិករួមការងារនីមួយៗ របស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា។
ក្នុងឆ្នាំ ២០២៤ យើងបានបន្តបំពេញបេសកកម្មរបស់យើងក្នុងការបង្កើតភាពរឹងមាំ ស្ថិរភាព និងការពឹងផ្អែកលើខ្លួនឯងតាមរយៈការសាងសង់លំនៅឋាន ទោះបីជានៅក្នុងកាលៈទេសៈដែលសកលលោកជួបវិបត្តិដែលមិនធ្លាប់មានពីមុនមកក្តី។

កិច្ចការរបស់យើងនៅក្នុងប្រទេសកម្ពុជាគឺតែងតែលើសពីការសាងសង់ផ្ទះជានិច្ច កិច្ចការរបស់យើងគឺការលើកកម្ពស់ជីវភាព និងសហគមន៍ឱ្យប្រសើរឡើងជាងមុន។ ក្នុងឆ្នាំនេះ ទោះបីជាមានជួបឧបសគ្គមួយចំនួន ដូចជាការប៉ះពាល់សល់ពីការរាតត្បាតជំងឺ និងបញ្ហាប្រឈមអាកាសធាតុក្តី យើងនៅតែតស៊ូពុះពារសម្របខ្លួន និងបន្តបង្កើតផលជះដែលមានរយៈពេលវែងដដែល។

សមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលដែលយើងមានមោទនភាពជាងគេនៅក្នុងឆ្នាំនេះ គឺការបញ្ចប់កិច្ចការក្នុងគំនិតផ្តួចផ្តើម “Home for All” ដែលយើងបានផ្តល់ជូនលំនៅឋានដែលមានសុវត្ថិភាព និងសមរម្យដល់គ្រួសារចំនួន **២,៣៧៤** នៅក្នុងសហគមន៍ខ្វះខាត។ វឌ្ឍនភាពដ៏សំខាន់មួយនេះគឺជាសក្ខីភាពដែលបង្ហាញពីផលជះនៃកិច្ចសហប្រតិបត្តិការ នវានុវត្តន៍ និងការតាំងចិត្តដ៏មោះមុតក្នុងការប្រឈមមុខនឹងបញ្ហា ហើយនេះគឺជាចំណុចដែលយើងមានមោទនភាពបំផុត។

ស្មារតីនៃការស្ម័គ្រចិត្ត និងការចូលរួមជាមួយសហគមន៍ដែលកំណត់អត្តសញ្ញាណអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងកម្មវិធីអ្នកដឹកនាំសាងសង់វ័យក្មេង ដែលសិស្សពីគ្រប់មជ្ឈដ្ឋានរួមគ្នាផ្តល់ភាពអង់អាចឱ្យគ្នាទៅវិញទៅមក ក៏ដូចជាសាងសង់លំនៅឋាន បង្កើតក្តីសង្ឃឹម និងអនាគតដល់អ្នកដែលត្រូវការ។ កម្មវិធីនេះបាននាំមកនូវការផ្លាស់ប្តូរជាក់ស្តែង និងបង្កើតជាស្មារតីសាមគ្គីភាព និងភាពអង់អាចដល់អ្នកចូលរួមគ្រប់គ្នា។

នាពេលអនាគត យើងប្តេជ្ញាចិត្តក្នុងការពង្រីកផលជះ និងការគ្របដណ្តប់របស់យើងបន្ថែមទៀតក្នុងប្រទេសកម្ពុជាតាមរយៈក្របខណ្ឌយុទ្ធសាស្ត្រថ្មីរបស់យើង “កសាង និងបង្កើតផលជះ”។ ការយកចិត្តទុកដាក់លើនិរន្តរភាព ភាពធន់ និងបរិយាបន្ន នឹងដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការបង្កើតពិភពលោកដែលមនុស្សគ្រប់រូបអាចរស់នៅក្នុងលំនៅឋានសមរម្យបាន។

យើងក៏មិនអាចសម្រេចកិច្ចការទាំងឡាយរបស់យើងបានដែរ ប្រសិនបើគ្មានការគាំទ្រពីម្ចាស់ជំនួយ ការខិតខំប្រឹងប្រែងរបស់អ្នកស្ម័គ្រចិត្ត ការតាំងចិត្តរបស់បុគ្គលិក និងស្មារតីតស៊ូរបស់សហគមន៍ដែលយើងកំពុងតែជួយនោះ។ ការចូលរួមរបស់អ្នកទាំងអស់គ្នា មិនថាតិច ឬច្រើន គឺជាកត្តាជំរុញចម្បងនៃភាពជោគជ័យនេះ។ ទាំងអស់គ្នា យើងបានបង្ហាញថា តាមរយៈការសហការគ្នា យើងអាចបង្កើតអនាគតភ្លឺស្វាងមួយដែលមានបរិយាបន្ន សម្រាប់បុគ្គលគ្រប់រូប។

សូមអរគុណសម្រាប់ការខិតខំគាំទ្រ ការជឿជាក់ និងភាពជាដៃគូរបស់លោកអ្នកនៅក្នុងបេសកកម្មរួមគ្នារបស់យើង។ ទាំងអស់គ្នា យើងនឹងលើកកម្ពស់សហគមន៍ឱ្យប្រសើរឡើងជាងមុន ម្តងមួយផ្ទះៗ។

ដោយសេចក្តីថ្លែងអំណរគុណ និងក្តីសង្ឃឹម



លោក សួន សុភាព

នាយកស្តីទីប្រចាំប្រទេស

នៃអង្គការលំនៅឋានមនុស្សជាតិកម្ពុជា

# ៣ ចក្ខុវិស័យ បេសកកម្ម និងគោលការណ៍របស់យើង



## ចក្ខុវិស័យ

ពិភពលោកមួយដែលមនុស្សគ្រប់គ្នាមានកន្លែងសមរម្យសម្រាប់រស់នៅ

## បេសកកម្ម

ស្វែងរកដើម្បីដាក់ចេញនូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅក្នុងសកម្មភាព អង្គការលំនៅឋានមនុស្សជាតិ ប្រមូលផ្តុំធនធានមនុស្ស ដើម្បីកសាងលំនៅឋាន សហគមន៍ និងក្តីសង្ឃឹម។

## គោលដៅ

នៅឆ្នាំ ២០៣០ ប្រជាជនយ៉ាងតិច ៧៥០ ០០០ នាក់ក្នុងប្រទេសកម្ពុជា ទទួលបានលំនៅឋានគ្រប់គ្រាន់ ដោយសមធម៌ និងមានភាពធន់នឹងអាកាសធាតុ។

# ៤ អំពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា

តាំងពីឆ្នាំ ២០០៣ មក អង្គការលំនៅឋានមនុស្សជាតិកម្ពុជា (អង្គការលំនៅឋានកម្ពុជា) បានផ្តល់ជំនួយដល់គ្រួសារចំនួន

**១៧៧.៣០០ គ្រួសារ**

ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់។ផលជះដ៏ទូលំទូលាយនៃលំនៅឋាននេះមានដូចជា ភាពប្រសើរឡើងជាងមុននៃជីវភាព សុខភាព ការអប់រំ សុខភាពផ្លូវចិត្ត ការការពារ សាមគ្គីភាពសង្គម និងភាពជាដៃគូជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ  និងក្នុងស្រុក ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនដៃគូ និងអាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិ។



# ៥ ទិដ្ឋភាពទូទៅនៅប្រទេសកម្ពុជា

ចំនួនប្រជាជនសរុប[១]
**១៦,៧ លាន**

ចំនួនប្រជាជននៅទីក្រុង[៤]
**២៥.១១%**

ចំនួនប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រ[២]
**១៧.៨%**

អត្រាស្ត្រីដែលមានកម្មសិទ្ធិផ្តាច់មុខ ឬរួមគ្នាលើលំនៅឋានមានចំនួន[៥]
**៤៨.៩%**

អត្រាប្រជាជនមិនមានការងារ[៣]
**0.៤%**

**គ្រោះធម្មជាតិមានដូចជាខ្យល់ព្យុះ ទឹកជំនន់ រន្ទះបាញ់ និងអគ្គិភ័យ[៧]**

បានកើតឡើង **១០១៨** ដង

ប្រជាជនចំនួន **១២៣** នាក់បានបាត់បង់ជីវិត

លំនៅឋានច្រើនជាង **១៨,000** ខ្នងត្រូវបានបំផ្លាញ

ប្រជាជនចំនួន **២៧៨** នាក់ត្រូវបានរងរបួស

**តម្រូវការលំនៅឋានដែលបានប៉ាន់ស្មាន**
នៅឆ្នាំ ២០៣០ ប្រទេសកម្ពុជានឹងត្រូវការលំនៅឋានថ្មីចំនួន **១.១ លាន** ខ្នង[៦]

**ប្រភព៖**

១. ធនាគារពិភពលោក ឆ្នាំ ២០២២
២. ការស្ទង់មតិសង្គមសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២០
៣. ធនាគារពិភពលោក ឆ្នាំ ២០២២
៤. គោលនយោបាយលំនៅឋានជាតិ ឆ្នាំ ២០២៤
៥. ធនាគារពិភពលោក ឆ្នាំ ២០២២
៦. ធនាគារពិភពលោក ឆ្នាំ ២០២២
៧. របាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ ២០២៣



# ៦ ក្របខណ្ឌយុទ្ធសាស្ត្ររបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា



**បេសកកម្ម**

ស្វែងរកដើម្បីដាក់ចេញនូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅក្នុងសកម្មភាព អង្គការលំនៅឋានមនុស្សជាតិ ប្រមូលផ្តុំធនធានមនុស្ស ដើម្បីកសាងលំនៅឋាន សហគមន៍ និងក្តីសង្ឃឹម។

**ចក្ខុវិស័យ**

ពិភពលោកមួយដែលមនុស្សគ្រប់គ្នាមានកន្លែងសមរម្យសម្រាប់រស់នៅ

**គោលដៅ**

នៅឆ្នាំ ២០៣០ ប្រជាជនយ៉ាងតិច ៧៥០ ០០០ នាក់ក្នុងប្រទេសកម្ពុជា ទទួលបានលំនៅឋានគ្រប់គ្រាន់ ដោយសមធម៌ និងមានភាពធន់នឹងអាកាសធាតុ។

**គំនិតផ្តួចផ្តើមសំខាន់ៗ**

**សាងសង់លំនៅឋានសមរម្យ ដោយសមធម៌ និងមានភាពធន់នឹងអាកាសធាតុ**

១) HOME-LIFT:ភាពអាចរស់នៅបាន ហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ប្តូរសិទ្ធិកាន់កាប់សម្រាប់ការអភិវឌ្ឍន៍នៅទីក្រុង និងជនបទ)

២) ភាពធន់របស់សហគមន៍

**ការធ្វើឲ្យមានឥទ្ធិពលដល់គោលនយោបាយ ប្រព័ន្ធ និងបទដ្ឋានដែលមានឥទ្ធិពលមកលើលំនៅឋាន តាមរយៈជម្រុញការចូលរួមក្នុងន័យស្ថាបនា *****

១) អភិបាលកិច្ច ការធ្វើបរិយាប័ន្ន និងការអភិវឌ្ឍន៍ទីផ្សារ

**កត្តាជំរុញការធ្លាក់ចុះ**

អង្គការលំនៅឋានឆ្លើយតបទៅនឹងកត្តាបង្កភាពតានតឹង និងការតក់ស្លុត ដែលនាំឱ្យកង្វះលំនៅឋានបន្តកើតមាន និងមានការកើនឡើង។

| | | | |
|---|---|---|---|
| **នគរូបនីយកម្ម** | **គោលនយោបាយ និង អភិបាលកិច្ច** | **ការប្រែប្រួលអាកាសធាតុ និង ព្រឹត្តិការណ៍រំខានផ្សេងៗ** | **ភាពក្រីក្រ និងការ អភិវឌ្ឍន៍សេដ្ឋកិច្ច** |

**ក្រុមគោលដៅ**

អង្គការលំនៅឋានធ្វើការជាមួយប្រជាជនដែលមានលក្ខខណ្ឌលំនៅឋានមិនសមរម្យ ដោយសារតែការមិនរាប់បញ្ចូលជាប្រព័ន្ធ និងភាពងាយរងគ្រោះ។

| | | |
|---|---|---|
| **អ្នកតាំងលំនៅឋានក្រៅផ្លូវការ** | **ស្ត្រី និង ជនងាយរងគ្រោះ *** | **អ្នកមានប្រាក់ចំណូលទាប*** |

## សាងសង់ និងឥទ្ធពល

*ដោយប្រើប្រព័ន្ធលំនៅឋានធម្មជាតិ និងវិធីសាស្ត្រផ្តោតលើប្រជាជន អង្គការលំនៅឋានមនុស្សជាតិកម្ពុជា ធ្វើការសហការបង្កើត និងអនុវត្តដំណោះស្រាយបញ្ហាលំនៅឋានប្រកបដោយបរិយាប័ន្ន និងសមធម៌ ដើម្បីដោះស្រាយដល់ផលប៉ះពាល់សង្គមដែលកំពុងមានការកើនឡើងយ៉ាងទូលំទូលាយ។*

**វិធីសាស្ត្រធ្វើការ៖** ការអនុវត្តផ្ទាល់ ការតស៊ូមតិ ប្រព័ន្ធទីផ្សារ ការងារស្ម័គ្រចិត្ត ភាពជាដៃគូ។

**ប្រធានបទពហុវិស័យ៖** រួមបញ្ចូលការពិចារណាលើកត្តាដែលជះឥទ្ធិពល យេនឌ័រ និងបរិស្ថាន ព្រមទាំងប្រើប្រាស់បច្ចេកវិទ្យា និងការងារស្ម័គ្រចិត្តក្នុងគម្រោង គំនិតផ្តួចផ្តើម និងនវានុវត្តភាព។

* **ជនងាយរងគ្រោះ៖** ឧ. កុមារកំព្រា និងក្រុមងាយរងគ្រោះ (យុវជន និងកុមារ) ជនក្រីក្រ (មិនលើសពី USD២.៧៥/ថ្ងៃក្នុងមនុស្សម្នាក់) ជនពិការ មនុស្សចាស់ ជនជាតិដើមភាគតិច ជនចំណាកស្រុក - លំនៅឋានភាគច្រើនប្រឈមនឹងហានិភ័យ។

** **ប្រាក់ចំណូលទាប៖** គ្រួសារដែលរកប្រាក់ចំណូលលើសពីបន្ទាត់នៃភាពក្រីក្រ (USD ២.៧៥/ថ្ងៃក្នុងមនុស្សម្នាក់រហូតដល់កម្រិតអតិបរមាដែលរាជរដ្ឋាភិបាលកម្ពុជា កំណត់ថាជាប្រាក់ចំណូលទាប។

*** **ជម្រុញការចូលរួមក្នុងន័យស្ថាបនា៖ (ក)** គឺជាការអនុវត្តសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋដែលបានរៀបចំឡើង ដើម្បីបម្រើផលប្រយោជន៍រួម ជាដំណើរការមួយដែលប្រមូលផ្តុំភាគីពាក់ព័ន្ធធ្វើសកម្មភាពឆ្លើយតបនឹងកង្វល់របស់ប្រជាពលរដ្ឋ ដែលត្រូវបានរៀបចំឡើង ដើម្បីធ្វើកំណែទម្រង់អភិបាលកិច្ច។ **(ខ)** វិធីសាស្ត្រនៃការស្វែងរកការគាំទ្រមតិឱ្យការផ្លាស់ប្តូរសង្គម និងការកែប្រែដែលទាមទារឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងសង្គមស៊ីវិល និងស្ថាប័នលើផ្នែកអភិបាលកិច្ច ដោយផ្អែកលើការគោរពគ្នាទៅវិញទៅមក ការជឿទុកចិត្ត នីត្យានុកូលភាព តម្លាភាព និងសមត្ថភាព។

# ៧ ផលជះក្នុងឆ្នាំ FY24 គ្រួសារដែលទទួលជំនួយពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា

ក្នុងឆ្នាំ FY24 អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបានផ្តល់ជំនួយដល់៖

**២.៣៧៤**
**គ្រួសារ**

ក្នុងការលើកកម្ពស់ជីវភាពរបស់ពួកគាត់តាមរយៈ៖ ការសាងសង់លំនៅឋាន បរិក្ខារទឹកស្អាត និងអនាម័យ និងកម្មវិធីអភិវឌ្ឍសហគមន៍

លំនៅឋានថ្មីចំនួន **៤៤** ខ្នង

បានជួសជុល និងកែលម្អលំនៅឋានចំនួន **៥៤** ខ្នង

លំនៅឋានកែលម្អ **០៦** ខ្នង

បានសាងសង់លំនៅឋានសរុបចំនួន **១០៤** ខ្នង







# ៨ គម្រោង HOME-LIFT៖

## ៨.១ លើកកម្ពស់ជីវភាពតាមរយៈ ការសាងសង់លំនៅឋាន

**រាម**បានរស់នៅដោយមានពិការភាពអស់រយៈពេល ៣០ ឆ្នាំមកហើយ បន្ទាប់ពីនាងបានជាន់មីននៅពេលកំពុងធ្វើការក្នុងវាលស្រែ។

ទោះបីជានាងត្រូវការឈើច្រត់ដើម្បីដើរក្តី នាងតែងតែខិតខំធ្វើការជានិច្ចដើម្បីជួយគាំទ្រដល់កូនទាំង ១៣ នាក់របស់នាង។ ជីវិតរបស់នាងកាន់តែមានស្ថានភាពលំបាកថែមទៀតនៅពេលដែលប្តីរបស់នាងបានទទួលមរណភាពប៉ុន្មានឆ្នាំមុន។

មុនពេលទទួលបានលំនៅឋានថ្មីពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា រាម និងសមាជិកគ្រួសារ ១១ នាក់ទៀត បានរស់នៅក្នុងខ្ទមលេចទឹកដ៏តូចចង្អៀតមួយ។ សព្វថ្ងៃ ជីវភាពរបស់ពួកគាត់បានល្អប្រសើរជាងមុនដោយសារតែមានផ្ទះធំទូលាយ និងរឹងមាំជាងមុន។

រាមពិតជាសប្បាយចិត្តណាស់ដែលកូន និងចៅរបស់គាត់អាចមានបរិវេណគ្រប់គ្រាន់ក្នុងការសម្រាកប្រកបដោយផាសុខភាព ហើយគាត់អាចសន្សំសំចៃប្រាក់បានច្រើនជាងមុនដោយមិនត្រូវចំណាយលើការជួសជុលញឹកញាប់។



*“ការទទួលបានផ្ទះនេះហាក់បីដូចជាទទួលបានឱកាសមានជីវិតលើកទីពីរអញ្ចឹង នៅអាយុ ៦០ ឆ្នាំ ខ្ញុំមិនដែលបានរំពឹងទុកថាខ្លួននឹងអាចមានលទ្ធភាពរស់នៅក្នុងផ្ទះធំ និងរឹងមាំបែបនេះឡើយ។”*

*“ឥឡូវនេះ ខ្ញុំមិនចាំបាច់ព្រួយបារម្ភអំពីការលេចទឹកក្នុងផ្ទះ ឬបាក់បែក ធ្លុះធ្លាយផ្ទះទៀតនោះទេ។”*





## ៨.២ លើកកម្ពស់ជីវភាពតាមរយៈក្រុមប៉ាសា (វិធីសាស្ត្រប៉ាន់ប្រមាណសុវត្ថិភាព លំនៅឋានតាមបែបចូលរួម)

មានសមាជិក
**១២៤** នាក់

(ស្ត្រី **៥៣** នាក់) ប៉ាសា






## ១០ ក្រុម (ក្រុមប៉ាសា និងក្រុមអ្នកផលិត)

ធ្វើការដើម្បីបំពេញតម្រូវការរបស់សហគមន៍ និងដោះស្រាយបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងអសន្តិសុខស្បៀងអាហារ។ វិធីសាស្ត្រប៉ាន់ប្រមាណសុវត្ថិភាពលំនៅឋានតាមបែបចូលរួម (ប៉ាសា) គឺជាវិធីសាស្ត្រក្នុងសហគមន៍ដែលមានគោលបំណងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជាពិសេសផ្តោតលើសុវត្ថិភាពលំនៅឋាន។

ក្នុងឆ្នាំFY24 (ពីខែកក្កដា ឆ្នាំ ២០២៣ ដល់ ខែមិថុនា ឆ្នាំ ២០២៤) អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានសហការជាមួយដៃគូដើម្បីបង្កើត និងបណ្តុះបណ្តាលក្រុមប៉ាសាចំនួន ១០ ក្រុម នៅក្នុងសហគមន៍ជនបទ និងជាយក្រុង ដែលរួមមានសមាជិកចំនួន

**១២៤**នាក់ ដែលមានស្ត្រីចំនួន **៥៣**នាក់

ក្រុមប៉ាសាអនុវត្តគម្រោងទាំងប្រាំបួនរបស់ខ្លួនដែលត្រូវបានទទួលថវិកាមួយផ្នែកពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា និងមួយផ្នែកទៀតបានពីការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ផ្ទាល់។

គម្រោងរបស់ប៉ាសាមានដូចជាការជួសជុលផ្លូវ កែលម្អប្រព័ន្ធលូខ្នាតតូច សាងសង់ស្ពាន សាងសង់កន្លែងលាងដៃ ទឹកស្អាតនៅសាលារៀន និងសហគមន៍។ សមិទ្ធផលទាំងនេះបានផ្តល់ជូនអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ ចំនួន ១,៨១៩ គ្រួសារដែលស្មើនឹង

**៩,៣៨២**នាក់ ដែលរួមមានស្ត្រីចំនួន **៤,៧៤៤**នាក់

ជាងនេះទៅទៀត ក្រុមប៉ាសាបានដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋានដើម្បីដាក់បញ្ចូលតម្រូវការអាទិភាពរបស់សហគមន៍ចូលទៅក្នុងផែនការវិនិយោគឃុំ និងជំរុញឱ្យមានការផ្តល់សិទ្ធិកាន់កាប់ដីធ្លីជាដើម។

# លើកកម្ពស់ជីវភាពតាមរយៈ ហេដ្ឋារចនាសម្ព័ន្ធ និងសាមគ្គីភាព





ជាផ្នែកមួយនៃគម្រោង BRRC នៅក្នុងឃុំស្ពៅ ខេត្តព្រះវិហារ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានបង្កើតក្រុមប៉ាសាដែលមានសមាជិកចំនួន ២១ នាក់ ភាគច្រើនជាស្ត្រី ដើម្បីដោះស្រាយបញ្ហាការគ្រប់គ្រងគ្រោះមហន្តរាយ និងហេដ្ឋារចនាសម្ព័ន្ធ។ ក្រុមនេះបានផ្តល់អាទិភាពជាចាំបាច់ទៅលើការសាងសង់ជួសជុលស្ពានដែលខូចខាតសម្រាប់បម្រើដល់ការដឹកជញ្ជូន និងសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់។ ជាមួយនឹងហិរញ្ញប្បទានចំនួន

## ៣០០០$

ដែលទទួលបានពីគម្រោង BRRC និងវិភាគទានពីសហគមន៍បន្ថែម យើងបានសាងសង់ស្ពានឈើដែលរឹងមាំមួយ មានប្រវែង ៩x៤ ម៉ែត្រក្នុងចំនួនទឹកប្រាក់សរុបចំនួន

## ៣,៣៧៥$

## ស្ពានថ្មីនេះ

ដែលត្រូវបានរចនាឡើងឱ្យធន់នឹងអាកាសធាតុអាក្រក់ បានផ្តល់ឱកាសឱ្យប្រជាជនអាចចូលទៅកាន់ទីផ្សារ សាលារៀន និងទទួលបានសេវាវេជ្ជសាស្ត្របានដោយងាយស្រួលជាងមុន ដែលជំរុញឱ្យមានសាមគ្គីភាពក្នុងសហគមន៍ និងជំរុញឱ្យមានវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គម។








## ៨.៣ លើកកម្ពស់ជីវភាព
## តាមរយៈការផ្លាស់ប្តូរសិទ្ធិកាន់កាប់

**១៦១**

គ្រួសារ ទទួលបានសិទ្ធិ
កាន់កាប់ដីធ្លី

**២៧**

គ្រួសារ ទទួលបានលិខិត
សម្គាល់កម្មសិទ្ធិដីធ្លី

**១៣៦**

គ្រួសារ ទទួលបានបង្កាន់ដៃដីធ្លី







## ការធានាសុវត្ថិភាពដីធ្លីនាពេលអនាគត

ខែមេសា ឆ្នាំ ២០២៤

**២៧**
គ្រួសារ

ពីក្រុមសហគមន៍ឡូតដូអភិវឌ្ឍក្នុងក្រុងបាត់ដំបង បានធ្វើការអបអរនូវសមិទ្ធផលដ៏សំខាន់ក្នុងការដែលពួកគេទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការពីរដ្ឋាភិបាល។ សមិទ្ធិផលនេះកើតចេញពីការតស៊ូមតិ និងការសហការគ្នារវាងសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ជាច្រើនឆ្នាំមកហើយ។

> *“ខ្ញុំធ្លាប់ព្រួយបារម្ភឥតល្ហែរពីលទ្ធភាពនៃការផ្លាស់ទីលំនៅម្តងទៀត ប៉ុន្តែពេលនេះ ខ្ញុំពិតជាដឹងគុណនូវការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីធានាសុវត្ថិភាព។ នេះគឺពិតជាមានប្រយោជន៍ទៅដល់កេរមរតករបស់ខ្ញុំ ដោយធានាបាននូវអនាគតដ៏ស្ថិតស្ថេរសម្រាប់កូនចៅរបស់ខ្ញុំ។ ខ្ញុំនឹងធ្វើអ្វីៗគ្រប់យ៉ាងទាំងកម្លាំងកាយចិត្តដើម្បីការពារដី និងផ្ទះរបស់ខ្ញុំ ហើយខ្ញុំនឹងមិនបោះបង់ទេ។”*

ឈ្មោះ យិប សាយ អាយុ ៧៨ឆ្នាំ អ្នកភូមិឡូតដូ។





# ៩ ភាពធន់របស់សហគមន៍

## ៩.១ ការបង្កើតសហគមន៍ដែលមានចីរភាព

អង្គការលំនៅឋានមនុស្សជាតិ និង អង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិគូសបញ្ជាក់ថា ការមានលំនៅឋានសមរម្យគឺពិតចាំបាច់ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ លំនៅឋានសមរម្យគឺលើសពីជម្រកនៅធម្មតា រួមទាំងរាប់បញ្ចូលនូវទិដ្ឋភាពផ្សេងៗដូចជា ឯកជនភាព សុវត្ថិភាព ហេដ្ឋារចនាសម្ព័ន្ធ និងលទ្ធភាពទទួលបាននូវសេវាកម្ម។ ទស្សនវិស័យដ៏ស៊ីជម្រៅនេះជួយលើកកម្ពស់ដល់ភាពធន់ សុខភាព និងការអប់រំ ស្របពេលដែលជំរុញឱ្យមានការផ្សារភ្ជាប់ក្នុងសហគមន៍ និងគាំទ្រដល់ស្ថិរភាពសេដ្ឋកិច្ច។ នៅក្នុង ឆ្នាំFY24 អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានផ្តោតទៅលើការផ្លាស់ប្តូរលំនៅឋាន អនាម័យ ភាពធន់នឹងគ្រោះមហន្តរាយ និងការផ្តល់ភាពអង់អាចដល់សហគមន៍ តាមរយៈគំនិតផ្តួចផ្តើមផ្សេងៗ ធ្វើឱ្យមានវឌ្ឍនភាពក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការលើកកម្ពស់គុណភាពជីវិតរបស់មនុស្សជាច្រើននាក់។



តារាងខាងក្រោមបង្ហាញពីសមិទ្ធផលសំខាន់ៗកើតចេញពីគំនិតផ្តួចផ្តើមរបស់យើងក្នុងឆ្នាំFY24 ដែលបង្ហាញពីផលជះវិជ្ជមានដែលយើងមានទៅលើគ្រួសារ និងសហគមន៍ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ សមិទ្ធផលនេះសង្កត់ធ្ងន់ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់យើងដែលផ្តោតលើសពីការផ្តល់នូវលំនៅឋាន ដោយឆ្លុះបញ្ចាំងពីការរួមចំណែកដោយផ្ទាល់ ឬដោយប្រយោលដើម្បីយើងអាចឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលជំរុញឱ្យមានការផ្លាស់ប្តូរ និងលើកកម្ពស់ភាពធន់នៅក្នុងសហគមន៍ប្រកបដោយចីរភាព។

## ការចូលរួមចំណែកដល់គោលដៅដោយផ្ទាល់៖

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១១-ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព៖**លំនៅឋានជំរុញវឌ្ឍនភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សាងសង់ និងកែលម្អផ្ទះ ផ្លូវថ្នល់ ប្រព័ន្ធលូ និងថាមពលដើរដោយពន្លឺព្រះអាទិត្យ ដោយពង្រឹងទាំងសហគមន៍នៅក្នុងទីក្រុង និងជនបទ។ យើងក៏កែលម្អការតាំងទីលំនៅក្រៅផ្លូវការ និងសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានដំណោះស្រាយលំនៅឋានតម្លៃសមរម្យផងដែរ។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦-ទឹកស្អាត និងអនាម័យ៖** ការទទួលបាននូវទឹកដែលមានសុវត្ថិភាពតម្លៃសរម្យ និងអនាម័យ គឺជាសិទ្ធិមនុស្ស ហើយក៏ជាធាតុចូលសំខាន់មួយនៃលំនៅឋានដែលមានភាពសមរម្យ និងសុខភាពល្អ។ អង្គការលំនៅឋានកម្ពុជា បានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងក្រុម ប៉ាសា ដើម្បីសាងសង់ប៉មស្តុកទឹកនៅសាលារៀន និងកន្លែងលាងដៃដែលផ្សារភ្ជាប់គ្រួសារទៅនឹងទឹក និងបង្គន់ស្អាត។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៣-សកម្មភាពបរិស្ថាន៖** លំនៅឋានប្រកបដោយចីរភាពជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សាងសង់ផ្ទះធន់នឹងតំបន់អាកាសធាតុត្រូពិចក្នុងប្រទេសកម្ពុជា កាត់បន្ថយហានិភ័យ និងការពង្រឹងសហគមន៍ទប់ទល់នឹងគ្រោះធម្មជាតិជាយថាហេតុ។ យើងក៏ផ្តល់ការបណ្តុះបណ្តាលអ្នកភូមិនូវការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយដើម្បីឱ្យពួកគាត់ស៊ាំខ្លួនទៅនឹងអាកាសធាតុ។

## ការរួមចំណែកដោយប្រយោលចំពោះគោលដៅ៖

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១-ពុំមានភាពក្រីក្រ៖** លំនៅឋានសមរម្យកាត់បន្ថយនូវភាពងាយរងគ្រោះចំពោះវិបត្តិសេដ្ឋកិច្ច សង្គម សុខភាព និងបញ្ហាទាក់ទងនឹងអាកាសធាតុ។អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សាងសង់ផ្ទះដែលមានស្ថិរភាព និងសុវត្ថិភាព រួមទាំងជាដៃគូជាមួយភាគីពាក់ព័ន្ធក្នុងការតស៊ូមតិដើម្បីឱ្យមានតម្លៃលំនៅឋានសមរម្យ សិទ្ធិដីធ្លី និងការរស់រានមានជីវិតប្រកបដោយចីរភាព។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំប្រកបដោយគុណភាព៖** លំនៅឋានប្រកបដោយស្ថិរភាព និង សុវត្ថិភាពបង្កើតឱកាសកាន់តែល្អប្រសើរដល់សិស្សានុសិស្សក្នុងការរៀនសូត្រ និងរីកចម្រើន។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា គាំទ្រដល់ការអប់រំតាមរយៈកម្មវិធីបណ្តុះបណ្តាល និងការកសាងសមត្ថភាពក្នុងការអភិវឌ្ឍន៍ន៍ប្រកបដោយចីរភាព ការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងការសាងសង់ប្រកបដោយគុណភាព។ យើងក៏រៀបចំព្រឹត្តិការណ៍ចែករំលែកចំណេះដឹងទាក់ទងនឹងច្បាប់ស្តីពីលំនៅឋាន សុខភាព និងអាកាសធាតុ ពង្រឹងអំណាចដល់សហគមន៍តាមរយៈការផ្តល់ចំណេះដឹង និងជំនាញសំខាន់ៗ។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣-សុខភាព និងសុខុមាលភាពមាំមួន៖** លំនៅឋានប្រកបដោយស្ថិរភាព និង សុវត្ថិភាព គឺពិតជាមានសារៈសំខាន់ចំពោះសុខភាពផ្លូវកាយ និងផ្លូវចិត្ត។ នៅក្នុងឆ្នាំFY24 អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានសាងសង់ផ្ទះធន់នឹងអាកាសធាតុ បន្ទប់ទឹក ប៉មស្តុកទឹកនៅសាលារៀន និងកន្លែងលាងដៃ ខណៈពេលដែលផ្តល់ការបណ្តុះបណ្តាល និងឧបករណ៍បង្ការជំងឺកូវីដ-១៩ ដែលបានផ្តល់អត្ថប្រយោជន៍ដល់គ្រួសារ សិស្សានុសិស្ស និងសហគមន៍ទាំងមូល។

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៩-( ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ )៖** បច្ចេកវិទ្យាថ្មីផ្តល់នូវដំណោះស្រាយលំនៅឋាន តម្លៃសមរម្យប្រកបដោយភាពធន់ និងមិនប៉ះពាល់ដល់បរិស្ថាន។ តាមរយៈកម្មវិធីភាពធន់ក្នុងសហគមន៍របស់យើង យើងសហការជាមួយក្រុមប៉ាសា និងភាគីពាក់ព័ន្ធដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅលើទីតាំងលំនៅឋានក្រៅផ្លូវការ ដោយធ្វើឱ្យប្រសើរឡើងនូវផ្ទះ បង្គន់ ជំឡើងបង្គោលថាមពលដើរដោយពន្លឺព្រះអាទិត្យ និងដាក់ឱ្យប្រើប្រាស់បច្ចេកទេសកសិកម្មប្រកបដោយនវានុវត្តន៍សម្រាប់ការដាំដុះស្បៀងតាមផ្ទះ។

## ៩.២ ការសាងសង់លំនៅឋានដែលធន់នឹងអាកាសធាតុ

ដោយសារតែពិភពលោកកំពុងតែជួបប្រទះនូវវិបត្តិអាកាសធាតុកាន់តែធ្ងន់ធ្ងរដោយសារតែការប្រែប្រួលអាកាសធាតុ ប្រទេសកម្ពុជាក៏មិនអាចរួចផុតដែរ។ នាឆ្នាំថ្មីៗនេះ ប្រទេសនេះជួបប្រទះនូវការកើនឡើងរលកកម្តៅយ៉ាងខ្លាំង រួមទាំងខ្យល់បក់ខ្លាំង ព្យុះ និងទឹកជំនន់ទូទាំងតំបន់។ ក្រុមវិស្វកររបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបានដោះស្រាយបញ្ហាប្រឈមដោយការសាងសង់ផ្ទះដែលធន់នឹងអាកាសធាតុសម្រាប់ម្ចាស់ផ្ទះ។ ជួបជាមួយលោក សយ ពិសិដ្ឋ ដែលជាអ្នកសម្របសម្រួលផ្នែកសាងសង់ គាត់នឹងចែករំលែកពីយុទ្ធសាស្ត្រទាំង ៥ សំខាន់ៗ ដែលអង្គការលំនៅឋានមនុស្សជាតិកម្ពុជាប្រើប្រាស់សម្រាប់សាងសង់ផ្ទះធន់នឹងផលជះអាកាសធាតុ។

**ប្រព័ន្ធស្តុកទឹក៖**
ផ្ទះនីមួយៗមានប្រព័ន្ធស្តុកទឹកភ្លៀង ដោយមានបំពាក់បំពង់សម្រាប់ប្រមូលទឹកភ្លៀងពីដំបូលចូលក្នុងធុងស្តុកឬពាងទឹក ដើម្បីផ្តល់ការផ្គត់ផ្គង់ទឹកប្រើប្រាស់ប្រចាំថ្ងៃ។

**ប្រព័ន្ធត្រជាក់អកម្ម៖**
ផ្ទះនីមួយៗមានបង្អួចបួនជ្រុង ដើម្បីអាចឱ្យខ្យល់ចេញចូល។ ដំបូលស័ង្កសីពណ៌ភ្លឺឆ្លុះកំដៅ និងមានអ៊ីសូឡង់ដាក់នៅខាងក្រោមដើម្បីកាត់បន្ថយកម្តៅជ្រាបចូលផងដែរ។



**ការដាំរុក្ខជាតិ៖**
ម្ចាស់ផ្ទះត្រូវបានលើកទឹកចិត្តឱ្យដាំបន្លែជុំវិញផ្ទះដើម្បីបង្កើនគុណភាពខ្យល់ ផ្តល់ម្លប់នៅរដូវប្រាំង និងការប្រមូលផលអាហារ ក៏ដូចជាការបង្កើនប្រាក់ចំណូលពីការលក់ផងដែរ។

**ភាពធន់នឹងទឹកជំនន់ និង ខ្យល់បក់ខ្លាំង៖**
ផ្ទះត្រូវបានសង់នៅលើគ្រឹះខ្ពស់ដើម្បីកាត់បន្ថយហានិភ័យទឹកជំនន់ និងបង្កើតកន្លែងទំនេរទុកសម្រាប់ប្រើប្រាស់។ ប្រព័ន្ធរចនាសម្ព័ន្ធត្រូវបានរចនាឡើងដើម្បីទប់ទល់នឹងខ្យល់បក់ខ្លាំងដោយធានាបាននូវសុវត្ថិភាព និងស្ថិរភាព។

**ថាមពលកកើតឡើងវិញ និងការរស់នៅប្រកបដោយចីរភាព៖** អង្គការលំនៅឋានមនុស្សជាតិកម្ពុជា ផ្តល់នូវការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជា បន្ទះសូឡាប្រើសម្រាប់សាកឧបករណ៍ និង អំពូល ក៏ដូចជាការណែនាំពីការផលិតអាហារនៅក្នុងស្រុក ដើម្បីគាំទ្រដល់ជីវិតរស់នៅប្រកបដោយចីរភាព។



**សយ ពិសិដ្ឋ**
អ្នកសម្របសម្រួលផ្នែកសាងសង់

តាមរយៈវិធីសាស្ត្រនេះ អង្គការលំនៅឋានមនុស្សជាតិកម្ពុជាសាងសង់ផ្ទះដែលមិនត្រឹមតែអាទប់ទល់នឹងបញ្ហាអាកាសធាតុតែប៉ុណ្ណោះទេ ថែមទាំងជំរុញឱ្យមានភាពធន់ និងប្រកបដោយចីរភាពដល់សហគមន៍ផងដែរ។

*❝ បើប្រៀបទៅនឹងខ្ទមចាស់របស់ខ្ញុំ ផ្ទះថ្មីនេះមានដំបូលខ្ពស់ និងអ៊ីសូឡង់នៅក្រោមដំបូល ដែលជួយកាត់បន្ថយកម្ដៅបានពាក់កណ្ដាល។ ផ្ទះមានបង្អួចដែលអាចឱ្យខ្យល់បរិសុទ្ធចេញចូលបាន និងបន្ទប់ជាន់ក្រោមដែលខ្ញុំអាចសម្រាកនៅពេលថ្ងៃ ដូច្នេះហើយខ្ញុំពុំចាំបាច់ពឹងផ្អែកខ្លាំងទៅលើកង្ហារអគ្គិសនីនោះទេ។ ផ្ទះនេះក៏មានប្រព័ន្ធស្តុកទឹកដែលជួយសន្សំសំចៃថាមពល និងកាត់បន្ថយតម្រូវការម៉ាស៊ីនបូមទឹក។ ខ្ញុំជឿថាការធ្វើបែបនេះជួយសន្សំសំចៃអគ្គិសនី។❞*

ឈិត រ៉េម ខេត្តសៀមរាប។





## ៩.៣ ដំណោះស្រាយទឹកស្អាត និងអនាម័យដែលមានចីរភាព

**៥៦** គ្រួសារ

**២៣០** នាក់ក្នុងនោះរួមមាន

**១៣០** នាក់ជាស្ត្រី

ទទួលបានទឹកដែលភ្ជាប់ពីបំពង់ទឹក ( ទឹកបានកែលម្អរួច ) ពីស្ថានីយ៍ទឹកក្នុងតំបន់ ដែលដំណើរការ និងគ្រប់គ្រងដោយគណៈកម្មការទឹកនៅក្នុងសហគមន៍។

## ៧៧ បន្ទប់ទឹកត្រូវបានសាងសង់

**២៧** បន្ទប់ទឹកថ្មី

**៥០** បន្ទប់ទឹកត្រូវបានសាងសង់នៅក្នុងផ្ទះថ្មី និងផ្ទះដែលបានជួសជុល

របាយការណ៍វាយតម្លៃបានបង្ហាញថា គំនិតផ្ដួចផ្ដើមទឹកស្អាត អនាម័យ និងការគ្រប់គ្រងកាកសំណល់ រួមមានការអប់រំ និងការកែលម្អបរិក្ខារ នាំឱ្យមានការផ្លាស់ប្ដូរអាកប្បកិរិយាជាវិជ្ជមានក្នុងចំណោមសមាជិកសហគមន៍។ ការស្ទង់មតិ និងការសម្ភាសន៍បានបញ្ជាក់ច្បាស់ពីភាពប្រសើរឡើងនូវការអនុវត្ត និងចំណេះដឹងទាក់ទងនឹងអនាម័យ និងការគ្រប់គ្រងកាកសំណល់ ដែលរួមចំណែកដល់ការរស់នៅពោរពេញទៅដោយសុខភាពល្អ



## ការពង្រឹងសហគមន៍តាមរយៈការអប់រំ អនាម័យសម្រាប់កុមារ

ជាផ្នែកមួយនៃគម្រោងការកសាងភាពធន់ និងពង្រឹងអំណាចដល់សហគមន៍ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា និង HelpAge Cambodia បានសហការគ្នាសាងសង់បង្គន់អនាម័យសម្រាប់ជនមានពិការភាពនៅសាលាបឋមសិក្សាអូរពងមាន់ និងសាលាបឋមសិក្សាតាគ្រាម ដែលជួយដល់

**១,២៣០**
**សិស្ស**

ក្នុងនោះរួមមានសិស្សមានពិការភាពចំនួនបួននាក់។ គ្រឿងបរិក្ខារដែលផ្តល់ភាពងាយស្រួល និងទើបនឹងសាងសង់ថ្មីនេះផ្តល់នូវអនាម័យជូនទៅកាន់កុមារគ្រប់រូប និងលើកកម្ពស់បរិយាបន្ន។

គំនិតផ្តួចផ្តើមនេះមិនត្រឹមតែលើកកម្ពស់ការអនុវត្តអនាម័យប៉ុណ្ណោះទេ ថែមទាំងជួយដល់សិស្សមានពិការភាព និងជំរុញការយល់ដឹងអំពីបរិស្ថានផងដែរ។



## ដំណោះស្រាយទឹកស្អាតប្រកបដោយនិរន្តរភាពសម្រាប់ភូមិសូច

ជាច្រើនឆ្នាំមកនេះ ប្រជាពលរដ្ឋរស់នៅភូមិសូចបានជួបការលំបាកក្នុងការប្រើប្រាស់ទឹកស្អាត ជាញឹកញាប់គឺតែងពឹងផ្អែកទៅលើប្រភពមិនមានសុវត្ថិភាព ឬក៏ការចំណាយខ្ពស់ទៅលើទឹកដែលមិនមានប្រព្រឹត្តកម្មត្រឹមត្រូវ ដែលនាំឱ្យមានបញ្ហាសុខភាពដូចជារាកជាដើម។ ដើម្បីដោះស្រាយបញ្ហានេះ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា, NTFP, និង World Vision Cambodia បានសាងសង់ស្ថានីយ៍ផ្គត់ផ្គង់ទឹកស្អាតនៅខែមីនា ឆ្នាំ 2024។ ដោយចំណាយទឹកប្រាក់វិនិយោគចំនួន

**$៥១,៨៩៩.៦៣**

ឥឡូវនេះ ស្ថានីយ៍បានផ្គត់ផ្គង់ទឹកស្អាតក្នុងតម្លៃសមរម្យ (២០០០រៀលក្នុងមួយម៉ែត្រគូប) ដល់ជាង

**៦២**

**គ្រួសារ**

ដែលជួយកាត់បន្ថយការចំណាយ ៧៥% និងជួយធ្វើឱ្យសុខភាពប្រសើរឡើង។ ប្រាក់ចំណេញត្រូវបានវិនិយោគឡើងវិញទៅក្នុងប្រតិបត្តិការ ថែទាំ និងការអភិវឌ្ឍន៍សហគមន៍ ធានាបាននូវចីរភាព។

យោងលើរបាយការណ៍វាយតម្លៃ គណៈកម្មការគ្រប់គ្រងទឹកបានបង្ហាញពីភាពជាម្ចាស់កម្មសិទ្ធិដ៏រឹងមាំ ដោយបានគ្រប់គ្រងស្ថានីយ៍តាំងពីខែកុម្ភៈ ឆ្នាំ ២០២៤ ប្រកបដោយភាពជោគជ័យ តាមរយៈការប្រមូលថ្លៃ បង្កើតច្បាប់ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពបច្ចេកទេស។ គម្រោងនេះមិនត្រឹមតែជួយកាត់បន្ថយបន្ទុកប្រចាំថ្ងៃ និងលើកកម្ពស់សុខភាពប៉ុណ្ណោះទេ ថែមទាំងពង្រឹងភាពធន់ក្នុងសហគមន៍ ដោយបង្ហាញពីផលជះនៃកិច្ចសហការសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពទៀតផង។



# ១០ សាងសង់ និងបង្កើតផលជះ៖

តាមរយៈការសាងសង់ និងបង្កើតផលជះ យើងបានសហការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារលំនៅឋានដើម្បីសាងសង់លំនៅឋានបន្ថែមសម្រាប់គ្រួសារផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងរបស់យើងក៏រួមបញ្ចូលការបណ្តុះបណ្តាល និងការតស៊ូមតិដែលមានគោលបំណងពង្រឹងភាពធន់របស់សហគមន៍ ដោយអប់រំប្រជាជនស្តីពីប្រធានបទសំខាន់ៗដូចជា ការលើកកម្ពស់ទឹកស្អាត និងអនាម័យ (WASH) បទបញ្ញត្តិលំនៅឋាន និងពិធីសារសុខភាពសម្រាប់ជំងឺកូវីដ ១៩។ យើងបានផ្សព្វផ្សាយជូនដល់សមាជិកសហគមន៍ និងសិស្ស ចំនួន ២,១២៣ នាក់ តាមរយៈកម្មវិធីបញ្ជ្រាបការយល់ដឹងដែលមានប្រសិទ្ធិភាព រំលេចលើបញ្ហាសំខាន់ៗដូចជាការអនុវត្តទឹកស្អាត និងអនាម័យ សិទ្ធិលំនៅឋាន និងយុទ្ធសាស្រ្តទប់ស្កាត់ជំងឺកូវីដ ១៩។

## ១០.១ សាងសង់ឱ្យបានច្រើនជាងមុន (MAATCH)



គម្រោង MAATCH (ការកៀរគរបច្ចេកវិទ្យា និងដើមទុនសមស្រប និងមានតម្លៃសមរម្យសម្រាប់សាងសង់លំនៅឋាន) បានចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៤ ដែលមានគោលបំណងពង្រឹងការផ្តល់ជូនទីជម្រក និងការតស៊ូមតិតាមរយៈភាពដៃគូបែបយុទ្ធសាស្រ្ត និងការស្វែងរកហិរញ្ញប្បទាន។ គម្រោងនេះផ្តល់ជូនជាឱកាសដើម្បីបម្រើដល់សហគមន៍តាមរយៈទាញអត្ថប្រយោជន៍ពីដើមទុន សង្គមនយោបាយ បច្ចេកវិទ្យា និងហិរញ្ញវត្ថុជាច្រើនទម្រង់។ តាមរយៈការផ្សព្វផ្សាយបន្ថែមអំពីផែនការសាងសង់លំនៅឋានជាមួយនឹងការសហការ និងការចូលរួមប្រកបដោយប្រសិទ្ធិភាព អង្គការលំនៅឋានមនុស្សជាតិកម្ពុជា មានតួនាទីជាអ្នកដឹកនាំ និងអ្នកសម្របសម្រួលដែលអាចទុកចិត្តបាននៅក្នុងប្រព័ន្ធនៃការសាង់សង់លំនៅឋាន។ លើសពីនេះទៀត គម្រោងនេះក៏មានគោលបំណងឆ្លើយតបប្រកបដោយប្រសិទ្ធិភាពទៅនឹងការផ្តល់ជូនដើមទុនពីភាគីពាក់ព័ន្ធដែលអាចផ្តល់ជូនហិរញ្ញប្បទាន និងកម្មវិធីចាប់ពីខ្នាតតូច ដល់ខ្នាតមធ្យម ដែលនឹងពង្រឹងផលជះរបស់គម្រោងនេះបន្ថែមទៀតក្នុងការដោះស្រាយនឹងបញ្ហាលំនៅឋាន។







## ការធ្វើបច្ចុប្បន្នភាពអំពីលទ្ធផលរបស់គម្រោង៖

នៅទីក្រុងភ្នំពេញ៖ ជាមួយនឹងសាលាហេបភីច័ន្ទតារាជាដៃគូ យើងបានផ្តល់ជូនលំនៅឋាន និងជំនួយផ្នែកកសិកម្មដល់សិស្សជានារី និងគ្រួសាររបស់ពួកគេ ហើយជាមួយនឹងអង្គការពិភពកុមារ និងអភិវឌ្ឍន៍ (PE&D) យើងបានលើកកម្ពស់ជីវភាព អនាម័យ និងលំនៅឋានសម្រាប់គ្រួសារក្រីក្រជាច្រើន។ លទ្ធផលរួមមានដូចជាការសាងសង់លំនៅឋានចំនួន៖

**២០** ខ្នង

ជួសជុល **៤១** ខ្នង

យើងក៏បានសាងសង់ផ្លូវថ្មើរជើង និងប្រព័ន្ធលូ ក៏ដូចជាផ្តល់ជូនការបណ្តុះបណ្តាលដល់

**៤៩** គ្រួសារ

នៅខេត្តបាត់ដំបង៖ យើងបានសហការជាមួយនឹងក្រុមហ៊ុន Tap Effect ដើម្បីផ្តល់ជូនទឹកស្អាតដល់គ្រួសារដែលបានផ្លាស់ទីលំនៅចំនួន

**៤៥៧** គ្រួសារ

ពង្រឹងអនាម័យ និងសមភាពយេនឌ័រ។ គម្រោងនេះក៏បានកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមរយៈការជួសជុលផ្លូវថ្នល់ និងប្រឡាយផងដែរ ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនចំនួន

**១,២៩១** នាក់

ហើយបានកែលម្អលំនៅឋានចំនួន ពីរផ្ទះជាមួយនឹងក្រុមប៉ាសាផងដែរ។



លោក អាល់ហ្វា យ៉ាយ៉ា បា
ប្រធានគ្រប់គ្រងគម្រោងអង្គការទូតទឹសអាឡេកូល

*“អង្គការរបស់យើងមានគោលដៅផ្តល់ជូនការអប់រំគុណភាពខ្ពស់ដល់កុមារី។ យើងមិនអាចផ្តល់ជូនការអប់រំគុណភាពខ្ពស់បានឡើយ ប្រសិនបើមិនមានបរិវេណល្អដែលពួកគាត់អាចលូតលាស់បាន។ គម្រោង MAATCH នេះបានផ្តល់ជូនសុវត្ថិភាពនៅផ្ទះដែលជួយឱ្យពួកគាត់អាចរៀនសូត្របានកាន់តែមានប្រសិទ្ធិភាព។”*

*“ការសហការជាមួយនឹងអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ក៏បានផ្តល់ឱកាសឱ្យយើងពង្រឹងលើការរចនាលំនៅឋានរបស់យើងផងដែរ ដើម្បីឱ្យមានភាពធន់នឹងអាកាសធាតុជាងមុន ដោយរក្សាទុកនូវរចនាបថស្ថាបត្យកម្មបែបវប្បធម៌ខ្មែរដដែល។ ឧទាហរណ៍ យើងមានរួមបញ្ចូលបរិវេណដែលអាចរស់នៅបាននៅជាន់ផ្ទាល់ដី និងរចនាលំនៅឋាននោះឱ្យផុតពីដី កម្ពស់ ២.២៥ ម៉ែត្រ ដើម្បីពួកគាត់អាចធ្វើកសិកម្មបានខ្លះ។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបានជួយយើងក្នុងការសម្រិតសម្រាំងការរចនាលំនៅឋានរបស់យើង ហើយផ្តល់ជូនដំណោះស្រាយដែលធ្វើឱ្យលំនៅឋានកាន់តែមានភាពបត់បែនខ្ពស់ជាងមុនចំពោះការប្រែប្រួលអាកាសធាតុ។ នេះពិតជាស្នាដៃដ៏អស្ចារ្យមែន!”*



## ១០.២ ការសហការដើម្បីស្វែងរកដំណោះស្រាយ៖ សិក្ខាសាលាស្តីពីបញ្ហាប្រឈមនៃលំនៅឋានសមរម្យក្នុងប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍន៍ទីក្រុង

ប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងខ្វះខាតលំនៅឋានសមរម្យចំនួន

**១.១ លានខ្នង**

នៅឆ្នាំ ២០៣០។ ដើម្បីដោះស្រាយបញ្ហានេះ សិក្ខាសាលានៅខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងខេត្តសៀមរាប ដែលបានរៀបចំឡើងដោយ UN-Habitat អង្គការលំនៅឋានមនុស្សជាតិកម្ពុជា និងអគ្គនាយកដ្ឋានលំនៅឋាន បានប្រមូលផ្តុំភាគីពាក់ព័ន្ធចំនួន ៩៤ នាក់ ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមរបស់លំនៅឋានភាពជាដៃគូ និងការកៀរគរធនធាន។ លទ្ធផលសំខាន់ៗរួមមានដូចជាផែនការសម្រាប់ក្រុមការងារ ការធ្វើផែនការយុទ្ធសាស្ត្រ និងការពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីស្វែងរកដំណោះស្រាយលំនៅឋានដែលមាននិរន្តរភាព។



## ១០.៣ បណ្តាញរបស់អង្គការមិនមែនរដ្ឋាភិបាលផ្នែកលំនៅឋានក្នុងប្រទេស កម្ពុជា

បណ្តាញលំនៅឋានក្នុងប្រទេសកម្ពុជា ដែលត្រូវបានផ្តួចផ្តើមឡើងដោយ UN-Habitat និងអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ជាមួយនឹងការគាំទ្រពីអគ្គនាយកដ្ឋានលំនៅឋាន មានគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការ និងការចូលរួមក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗ នៅក្នុងវិស័យលំនៅឋានសមរម្យ។ គំនិតផ្តួចផ្តើមនេះនឹងឆ្លើយតបនឹងតម្រូវការចាំបាច់ចំពោះលំនៅឋានថ្មីចំនួន

**១,១លានខ្នង**

នៅឆ្នាំ ២០៣០ ដែលនឹងបង្កើតជាថ្នាលរួមមួយដើម្បីប្រឈមមុខនឹងបញ្ហាប្រឈមរបស់លំនៅឋាននៅក្នុងប្រទេស។ ទោះបីជារដ្ឋាភិបាលចេញគោលនយោបាយដែលលើកកម្ពស់លំនៅឋានសមរម្យក្តី ថ្លៃដើមខ្ពស់នៅតែជាបញ្ហាដែល

**រារាំង៦0%**

នៃប្រជាជនសរុបពីការទទួលបានលំនៅឋានដែរ។ គោលដៅរបស់បណ្តាញនេះគឺដើម្បីប្រមូលផ្តុំអង្គការមិនមែនរដ្ឋាភិបាល លើកទឹកចិត្តការសហការជាដៃគូ និងតស៊ូមតិដើម្បីស្វែងរកដំណោះស្រាយដែលអាចជួយឱ្យប្រជាជនគ្រប់រូបអាចមានលំនៅឋានសមរម្យបាន។ បណ្តាញនេះនឹងយកចិត្តទុកដាក់លើការចែករំលែកការអនុវត្តល្អ បង្កើតភាពជាដៃគូ និងពង្រឹងសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាល។ គំនិតផ្តួចផ្តើមនេះមានគោលដៅសម្របកិច្ចខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល ឱ្យស្របនឹងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល បង្កើតកិច្ចសហប្រតិបត្តិការ និងពង្រឹងទំនាក់ទំនងដើម្បីឆ្លើយតបនឹងបញ្ហាលំនៅឋានដែលសហគមន៍ចំណូលទាប និងងាយរងគ្រោះកំពុងប្រឈម។







សិក្ខាសាលាស្តីពី
UN-HABITAT
Habitat for Humanity
Workshop on
"Engaging NGOs' Participation into the
Housing Sector of Cambodia"

# ១១ ការពង្រីកផលជះសង្គម តាមរយៈការស្ម័គ្រចិត្ត



**៥១៥**
ចំនួនអ្នកស្ម័គ្រចិត្តបរទេស

**២៣៧**
ចំនួនអ្នកស្ម័គ្រចិត្តបរទេស

**២៧៨**
ចំនួនអ្នកស្ម័គ្រចិត្តក្នុងស្រុក



## អ្នកដឹកនាំសាងសង់លំនៅឋានវ័យក្មេង ឆ្នាំ ២០២៤៖

មួយសប្តាហ៍មុនចូលឆ្នាំខ្មែរ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៤អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបានរៀបចំពិធីអ្នកដឹកនាំសាងសង់លំនៅឋានវ័យក្មេង ឆ្នាំ២០២៤ មួយដែលបានប្រមូលផ្តុំអ្នកស្ម័គ្រចិត្តចំនួន

**១៦២ នាក់**

ពីសាលាអន្តរជាតិផ្សេងៗជាច្រើន។ អ្នកស្ម័គ្រចិត្តទាំងអស់បានចូលរួមជាកម្លាំងនៅក្នុងសង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីផ្តល់ជំនួយដល់គ្រួសារចំនួន ៧ តាមរយៈសកម្មភាពដូចជាការសាងសង់លំនៅឋាន ការលាបពណ៌លំនៅឋាន និងរបងសាលារៀន ការលើកកម្ពស់អនាម័យ និងសម្អាតសហគមន៍។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគាត់បានបង្ហាញទឹកចិត្ត និងការសហការជាក្រុម ដែលបានបង្កើតជាផលជះដ៏វិជ្ជមានមួយសម្រាប់គ្រួសារទាំងនោះ។ យើងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្តទាំងអស់សម្រាប់ការខិតខំប្រឹងប្រែង និងការតាំងចិត្តរបស់ពួកគេ។





“ការគាំទ្រគំនិតផ្តួចផ្តើមនេះគឺពិតជាគួរឱ្យកោតសរសើរមែន។ ប្រជាជនគ្រប់រូបគួរតែចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍របស់យើងទាំងអស់គ្នា។ មនុស្សជាច្រើនអាចមានសំណាងទទួលបានជីវិតដែលមានផាសុខភាពជាមួយនឹងលំនៅឋានកក់ក្តៅ និងការអប់រំគុណភាពខ្ពស់។ ក៏ប៉ុន្តែ យើងមិនគួរមើលរំលងអ្នកដែលយើងកំពុងជួយនៅថ្ងៃនេះឡើយ ដែលពួកគាត់មិនមានឱកាសទទួលបានឯកសិទ្ធិទាំងនោះ។ ដូច្នេះ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកទាំងអស់គ្នាចាប់យកគ្រប់ឱកាសទាំងអស់ដែលដើម្បីចូលរួមផ្តល់ជំនួយដល់សង្គមយើងវិញ។ សូមអរគុណសម្រាប់ការចូលរួមរបស់អ្នកនៅថ្ងៃនេះ។”

ហង្ស ម៉ានីតា, បវរកញ្ញាចក្រវាលនៃ
ប្រទេសកម្ពុជា ឆ្នាំ២០២២



លោក ដើមេន

“ខ្ញុំពេញចិត្តនឹងបទពិសោធន៍ក្នុងការផ្តល់ជំនួយដល់សហគមន៍ និងជួយអ្នកដទៃខ្លាំងណាស់។ ខ្ញុំគិតថានេះជាសកម្មភាពដ៏ល្អ ហើយខ្ញុំក៏មានគោលដៅក្នុងជីវិតថា ចង់ជួយសាងសង់លំនៅឋានឱ្យអ្នកដទៃ ក្នុងអំឡុងពេលដែលខ្ញុំកំពុងបញ្ចប់ការសិក្សារបស់ខ្ញុំផងដែរ ដូច្នេះនៅពេលខ្ញុំធំឡើង ខ្ញុំចង់ជួយប្រជាជននៅក្នុងសហគមន៍បែបនេះឱ្យបានកាន់តែច្រើនថែមទៀត។”

# ១២ ទិដ្ឋភាពទូទៅហិរញ្ញវត្ថុ

## ចំណូល




## ចំណាយ







១៣

# សូមអរគុណ
# សម្រាប់ការសាងសង់
# ជាមួយយើង!

## ដៃគូ និងអ្នកផ្តល់ជំនួយអន្តរជាតិ

- លោកស្រី អាលីស និង លោកវ៉ល់ធើអាប្រាម
- ក្រុមហ៊ុន ASKUL
- អង្គការ Communities for Communities
- អង្គការ Community Chest of Korea
- ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី
- អង្គការលំនៅឋានមនុស្សជាតិអូស្ត្រាលី
- អង្គការលំនៅឋានមនុស្សជាតិចក្រភពអង់គ្លេស
- អង្គការលំនៅឋានមនុស្សជាតិអន្តរជាតិ
- អង្គការលំនៅឋានមនុស្សជាតិអៀរឡង់
- អង្គការលំនៅឋានមនុស្សជាតិជប៉ុន
- អង្គការលំនៅឋានមនុស្សជាតិកូរ៉េ
- អង្គការលំនៅឋានមនុស្សជាតិហូឡង់
- អង្គការលំនៅឋានមនុស្សជាតិសិង្ហបុរី
- មូលនិធិ Hilti Foundation
- មូលនិធិ Linden Root Dickinson Foundation
- ក្រុមហ៊ុន S.T Corporation
- ក្រុមហ៊ុន Samsung Electronics
- មូលនិធិ Charitable Foundation
- អង្គការ Touchstone
- អង្គការ WakaWaka

## ដង្វាយមួយភាគដប់

- Christopher W. Platt
- Habitat for Humanity Central Oklahoma
- Habitat for Humanity Flagler
- Habitat for Humanity Flatirons
- Habitat for Humanity Grants Pass Area
- Habitat for Humanity La Crosse Area
- Habitat for Humanity Lakeland
- Habitat for Humanity Midland
- Habitat for Humanity of Anderson
- Habitat for Humanity of Colorado
- Habitat for Humanity of Georgetown County SC
- Habitat for Humanity of Greater Cincinnati
- Habitat for Humanity of La Plata County
- Habitat for Humanity of Lee & Hendry Counties
- Habitat for Humanity of Northwest Connecticut
- Habitat for Humanity of the Charlotte Region
- Habitat for Humanity of the Greater La Crosse Region
- Habitat for Humanity of Wake County
- Habitat for Humanity Upper Cumberland
- Harlan Stone
- Hawaii Habitat for Humanity Association
- Robert S. Latimer

## ● អ្នកឧបត្ថម្ភសាជីវកម្មក្នុងស្រុក ដៃគូ

- សាលាអន្តរជាតិ Northbridge កម្ពុជា។

## ● ដៃគូ I/NGO ក្នុងស្រុក

- Winrock International-Cambodia
- ទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្មជនបទ (READA
- ផលិតផលព្រៃឈើមិនមែនឈើ (NTFP)
- អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច និងធនធានមនុស្ស (HURREDO)
- Planete Enfants and Development (PE&D)
- TOUTES A LECOLE (សាលារីករាយ ចាន់តារា)
- TapEffect CO., LTD
- Great Peace Cambodia (GPC)
- HelpAge Cambodia
- ក្រុមពង្រឹង និងអភិវឌ្ឍន៍សហគមន៍ (CEDT)

## ● សាកលវិទ្យាល័យ/សាលា៖

- សាលាបឋមសិក្សាឈូលាធំ
- Cambodia International Models
- សាលាអន្តរជាតិ CIA FIRST
- សាលាធុរកិច្ច TAYAMA
- សាលាអន្តរជាតិភ្នំពេញ
- សាលាអន្តរជាតិ Northbridge កម្ពុជា។
- សាលាបឋមសិក្សាសម្តេចតេជោ ហ៊ុន សែន រុនតាឯក
- សាលាបឋមសិក្សាថ្មឈុល
- សាលាបឋមសិក្សាតាក្រឹម
- សាលាបឋមសិក្សាអូរពងមាន់
- សាលាបឋមសិក្សាតាក្រឹម
- សាលាបឋមសិក្សាអូរពងមាន់

## ● ដៃគូរសហការរដ្ឋាភិបាលថ្នាក់ជាតិនិងក្រោមជាតិ

- ក្រសួងអភិវឌ្ឍន៍ជនបទ ( MRD )
- ក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានលំនៅឋាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ( MLMUPC )
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ
- រដ្ឋបាលខេត្តសៀមរាប
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប
- មន្ទីររៀបចំដែនការខេត្តសៀមរាប
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង សុរិយោដី ខេត្តសៀមរាប
- រដ្ឋបាលខេត្តបាត់ដំបង
- មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និង សុរិយោដី ខេត្តបាត់ដំបង
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង
- មន្ទីរផែនការខេត្តបាត់ដំបង
- រដ្ឋបាលខណ្ឌព្រែកព្នៅ
- សាលាខណ្ឌពោធិ៍សែនជ័យ
- ខណ្ឌសែនសុខ
- រដ្ឋបាលខណ្ឌច្បារអំពៅ

- រដ្ឋបាលស្រុកបន្ទាយស្រី
- រដ្ឋបាលស្រុកប្រាសាទបាគង
- មន្ទីរកសិកម្មស្រុកសង្គមថ្មី
- រដ្ឋបាលស្រុកសង្គមថ្មី
- រដ្ឋបាលក្រុងសៀមរាប
- រដ្ឋបាលខេត្តសៀមរាប
- រដ្ឋបាលស្រុកសូទ្រនិគម
- រដ្ឋបាលស្រុកវ៉ារិន
- រដ្ឋបាលក្រុងបាត់ដំបង
- រដ្ឋបាលក្រុងបវេល
- រដ្ឋបាលស្រុកសង្កែ
- រដ្ឋបាលស្រុកឯកភ្នំ
- រដ្ឋបាលស្រុកបាណន់
- រដ្ឋបាលស្រុកមោងឫស្សី
- សង្កាត់ត្រពាំងក្រសាំង
- សង្កាត់ចោមចៅ១
- រដ្ឋបាលសង្កាត់គោករកា
- សង្កាត់សំរោង
- សង្កាត់ឃ្មួញ
- រដ្ឋបាលសង្កាត់ព្រែកថ្មី
- រដ្ឋបាលឃុំដានរុន
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ
- រដ្ឋបាលឃុំព្រៃឈរ
- សាលាឃុំរអាង
- រដ្ឋបាលឃុំរុនតាឯក
- រដ្ឋបាលឃុំស្ពៅ
- រដ្ឋបាលឃុំស្រែណូយ
- រដ្ឋបាល ឃុំ ត្រពាំងធំ
- រដ្ឋបាលសង្កាត់ស្វាយប៉ោ
- រដ្ឋបាលសង្កាត់វត្តគរ
- រដ្ឋបាលសង្កាត់ព្រែកព្រះស្ដេច
- រដ្ឋបាលសង្កាត់ទួលតាឯក
- រដ្ឋបាលសង្កាត់រតនះ
- រដ្ឋបាលសង្កាត់ចំការសំរោង
- រដ្ឋបាលសង្កាត់ស្លាកែត
- រដ្ឋបាលសង្កាត់ក្ដុលដូនទាវ
- រដ្ឋបាលសង្កាត់ឱម៉ាល់
- រដ្ឋបាលសង្កាត់អូរចារ
- រដ្ឋបាលឃុំព្រែកនរិន្ទ
- មណ្ឌលសុខភាពព្រែកនរិន្ទ
- មណ្ឌលសុខភាពតាគ្រាម

## ● ស្ថានទូត

- ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា
- ស្ថានទូតសាធារណរដ្ឋសិង្ហបុរីប្រចាំកម្ពុជា

# សូមអរគុណដែលបានគាំទ្រដល់ពួកយើង

Australian Aid

communities for communities
building communities together

Community Chest of Korea

Habitat for Humanity® Australia

Habitat for Humanity® Ireland

한국해비타트
Habitat for Humanity® Korea

Habitat for Humanity®

Habitat for Humanity® Japan

ថតរូបដោយ៖
អ៊ុំ វណ្ណៈ
ជា ប៊ុនសេង (អេរិក)
ស៊ិង ប៊ុណ្ណា

# ព័ត៌មានទំនាក់ទំនង

## ការិយាល័យភ្នំពេញរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា


ផ្ទះលេខ ៤៨៧Eo ផ្លូវ ៥៣BT ក្រុម ៦ ភូមិក្បាលទំនប់ សង្កាត់បឹងទំពន់ II
ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ១២៣៥១

+៨៥៥(០)២៣ ៩៩៧ ៨៤០


## ការិយាល័យខេត្តសៀមរាប


ភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ប្រទេសកម្ពុជា

+៨៥៥(០)២៣ ៩៩៧ ៨៤០


## ការិយាល័យខេត្តបាត់ដំបង


ផ្ទះលេខ ២៨៦ ក្រុម ៧ ភូមិបែកចាន សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង
ខេត្តបាត់ដំបង ប្រទេសកម្ពុជា

+៨៥៥(០)២៣ ៩៩៧ ៨៤០


## ប្រសិនបើអ្នកមានយោបល់ ឬគំនិតសម្រាប់ការកែលម្អដល់កិច្ចការរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សូមទាក់ទងមកកាន់យើងខ្ញុំ៖


០១២ ៤៨១ ០៩៨

feedback@habitatcambodia.org

heal.habitat.org


សូមស្កែននៅ
ទីនេះ៖



# ចូលរួមជាមួយយើងខ្ញុំ

## បរិច្ចាគ

មិនថាតិច ឬច្រើន អំណោយហិរញ្ញវត្ថុរបស់លោកអ្នក នឹងជួយឱ្យអង្គការលំនៅឋានមនុស្សជាតិកម្ពុជាអាចជួយដល់គ្រួសារកាន់តែច្រើនជាងមុន និងសាងសង់លំនៅឋានដែលមានតម្លៃសមរម្យបន្ថែមទៀតនៅក្នុងប្រទេសកម្ពុជា។

## អ្នកស្ម័គ្រចិត្ត

លោកអ្នកក៏អាចចូលរួមជាមួយយើងក្នុងកម្មវិធីភូមិសកលរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា តាមរយៈការចុះកម្មសិក្សា ឬក្លាយជាអ្នកសាងសង់លំនៅឋានដោយចូលទៅកាន់វេបសាយត៍

http://www.habitat.org/cd/gv/schedule.aspx

## ទាក់ទងជាមួយនឹងបណ្តាញសង្គមរបស់យើង

តាមដានសកម្មភាពរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជាតាមរយៈតំណរភ្ជាប់បណ្តាញសង្គមរបស់យើងដូចខាងក្រោម

- HabitatCambodia1
- Habitat Cambodia
- HabitatCambodia
- Habitat Cambodia
- habitatcambodia.org

